ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Cour Suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 07-Jun-2019, 15:09
CMS/CFO: Sann Rada

| | |
|---|---|
| នៅចំពោះមុខ: | **ចៅក្រម គង់ ស្រីម ប្រធាន** |
| | **ចៅក្រម Chandra Nihal JAYASINGHE** |
| | **ចៅក្រម សោម សិរីវឌ្ឍ** |
| | **ចៅក្រម Florence Ndepele Mwachande MUMBA** |
| | **ចៅក្រម ម៉ុង មុន្នីចរិយា** |
| | **ចៅក្រម Phillip RAPOZA** |
| | **ចៅក្រម យ៉ា ណារិន** |
| កាលបរិច្ឆេទ: | **ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៩** |
| ភាសា: | **ខ្មែរ/អង់គ្លេស** |
| ចំណាត់ថ្នាក់ឯកសារ: | **សាធារណៈ** |

---

# សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឱ្យពិចារណាឡើងវិញនូវសេចក្តីសម្រេចអំពី ការស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ

---

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**

នួន ជា
ខៀវ សំផន

01617641



**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Marie GUIRAUD

**<u>មេធាវីជនជាប់ចោទ</u>**

សុន អារុន

Doreen CHEN

គង់ សំអុន

Anta GUISSÉ

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់ទោសឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក")

**កត់សម្គាល់**សំណើរបស់ ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញនូវសេចក្ដីសម្រេចលើសំណើសុំបន្ថែមពេល និង ចំនួនទំព័រលើសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៩ ("សំណើសុំ")[1] ដែល ស្នើសុំឱ្យធ្វើការពិចារណាឡើងវិញនូវការបន្ថែមពេលវេលា និងចំនួនទំព័រ ដែលផ្ដល់ដោយអង្គជំនុំជម្រះតុលាការ កំពូលក្នុងការដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ("សេចក្ដីសម្រេច")[2] ដោយផ្អែកលើការលើកឡើងទាំងអស់ នៅក្នុងសំណើទីមួយ[3] និងចម្លើយតបបន្ទាប់របស់ ខៀវ សំផន ទៅនឹងសហព្រះរាជអាជ្ញា និងសហមេធាវីនាំ មុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី[4]

**សង្កេតឃើញ**ថា វិធានផ្ទៃក្នុងពុំបានផ្ដល់មូលដ្ឋានផ្លូវច្បាប់សម្រាប់ការពិនិត្យ និងការពិចារណាឡើងវិញនូវសេចក្ដី សម្រេចដែលចេញរួចហើយ

**ទោះជាយ៉ាងណាកត់សម្គាល់ឃើញ**ថា អង្គជំនុំជម្រះតុលាការកំពូលអាចពិចារណាឡើងវិញលើសេចក្ដីសម្រេច ដែលខ្លួនចេញរួចហើយ ប្រសិនបើមានកំហុសកើតឡើង ឬប្រសិនបើមានករណីចាំបាច់ក្នុងការរារាំងភាពមិន យុត្តិធម៌[5]

---

[1] សំណើរបស់ ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញលើសេចក្ដីសម្រេចស្ដីពីការសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រសម្រាប់ដាក់សេចក្ដី ជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៩ ឯកសារលេខ F44។

[2] សេចក្ដីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រ លើសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F43។

[3] សំណើរបស់ ខៀវ សំផន សុំពន្យារពេល និងបន្ថែមចំនួនទំព័រនៃសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F39/1.1 (ជូនដំណឹងនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៩)។

[4] ចម្លើយតប និងសារណាតបរបស់ ខៀវ សំផន ទៅនឹងសហព្រះរាជអាជ្ញាស្ដីពីការបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សេចក្ដី ជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F41/1 (ជូនដំណឹងនៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៩) ("ចម្លើយតបទៅនឹងសហព្រះរាជអាជ្ញា")។ ចម្លើយតបរបស់ ខៀវ សំផន ទៅនឹងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពី ការបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រនៃសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F42/1 (ជូនដំណឹងនៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៩) ("ចម្លើយតបទៅនឹងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី")។

[5] *សូមមើល ឧ. រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Ratko Mladić* សំណៅសាធារណៈត្រូវបានកោសលុប "សេចក្ដីសម្រេចលើសំណើសុំការពិចារ ណាឡើងវិញ និងការបញ្ជាក់ចំពោះសេចក្ដីសម្រេចនៃបណ្ដឹងសាទុក្ខលើសំណើសុំមោឃភាពសាលក្រម និងព្យួរកិច្ចដំណើរការនីតិវិធី" សំណុំរឿងលេខ MICT-13-56-A ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៨ ទំព័រ ២។

**កត់សម្គាល់ឃើញ**ថា ដោយផ្ទុយពីការអះអាងរបស់ ខៀវ សំផន[6] អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យលើចំណុចពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបញ្ហានៅចំពោះមុខខ្លួន

**ពិចារណាឃើញ**ថា សំណើរបស់ ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញ ជាការលើកច្រំដែលទាំងស្រុងនូវសំណើសុំទីមួយរបស់ខ្លួន និងចម្លើយតប ជាពិសេសពាក់ព័ន្ធទៅនឹងភាពស្មុគស្មាញនៃសំណុំរឿង ០០២/០២ បើធៀបនឹងសំណុំរឿង ០០២/០១ និងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌដែលមានលក្ខណៈអន្តរជាតិ និងការលើកឡើងពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទដែលបានស្នើឡើងសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២[7]

**កត់សម្គាល់ឃើញ**ថា អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើសារណារបស់ភាគី ហើយក្នុងសេចក្តីសម្រេចរបស់ខ្លួន បានផ្តល់ការបន្ថែមពេលវេលា និងចំនួនទំព័រ បន្ទាប់ពីបានធ្វើការវាយតម្លៃជារួមទៅលើកត្តានានាដូចបានបង្ហាញនៅក្នុងនោះ[8]

**កត់សម្គាល់ឃើញ**ថា សំណើសុំកែតម្រូវរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានដាក់នៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៩[9] បានធ្វើទៅលើកំហុសពាក់ព័ន្ធនឹងការគ្រប់គ្រងឯកសារ ដូចជា ការច្រឡំឯកសាររបស់អ្នកធ្វើកិច្ចសម្ភាសន៍ និងការបកប្រែសេចក្តីដកស្រង់មួយចេញពីសៀវភៅរបស់ ខៀវ សំផន *ការពិចារណាលើប្រវត្តិសាស្ត្ររបស់កម្ពុជាចាប់តាំងពីដំណាក់កាលដំបូងរហូតដល់អំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ* ពុំមានកំហុសណាមួយពាក់ព័ន្ធនឹងការកែប្រែខ្លឹមសារ ឬប៉ះពាល់សាលក្រមឡើយ

**ពិចារណាទៅលើ**ភាពចាំបាច់ក្នុងការធានាឱ្យបាននូវកិច្ចដំណើរការនីតិវិធីឆាប់រហ័ស ដោយស្របតាមក្របខ័ណ្ឌការងារផ្នែកច្បាប់របស់ អ.វ.ត.ក និងបទដ្ឋានអន្តរជាតិ[10]

**ពិចារណាឃើញ**ថា របបដាច់ដោយឡែកពីគ្នានៃវិធានផ្ទៃក្នុងសម្រាប់ការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណា មានគោលបំណងខុសៗគ្នា និងថា ជាពិសេស ការរៀបចំសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ គឺជា

---

[6] សំណើសុំពិនិត្យឡើងវិញ កថាខណ្ឌ ៥ ដល់ ៦។

[7] សំណើសុំពិនិត្យឡើងវិញ កថាខណ្ឌ ៥ ដល់ ៦, ៨ ដល់ ៩ និង ១២។ *សូមមើលផងដែរ* សំណើទីមួយ កថាខណ្ឌ ១៨ ដល់ ២៣។ ចម្លើយតបទៅនឹងសហព្រះរាជអាជ្ញា កថាខណ្ឌ ១៤ និង ១៨ ដល់ ២៤។

[8] សេចក្តីសម្រេច កថាខណ្ឌ ៨ ដល់ ១០។

[9] សំណើសុំកែតម្រូវ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ E465/Corr-1 (ដាក់នៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៩)។ *សូមមើលផងដែរ* សំណើសុំពិនិត្យឡើងវិញ កថាខណ្ឌ ១២។

[10] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់ទោសឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ មាត្រា ៣៣ ថ្មី, ៣៧ ថ្មី។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា ១៤(៣)(គ) និង ១៤(៥)។

នីតិវិធីមួយក្នុងគោលបំណងកម្រិតអំពីពេលវេលា និងខ្លឹមសារ បើធៀបទៅនឹងការរៀបចំ និងការដាក់សារណា នៃបណ្តឹងសាទុក្ខដែលមានសម្អាងហេតុពេញលេញ[11]

**ពិចារណាបន្ថែមទៀតឃើញ**ថា សហមេធាវីការពារក្តី ខៀវ សំផន ត្រូវបានបន្តផ្តល់អាណត្តិជាមេធាវីការពារក្តីសម្រាប់អំឡុងពេលនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ហើយត្រូវបានផ្តល់តួនាទីសំខាន់ក្នុងការកំណត់អំពីកំហុសអង្គច្បាប់ដែលនាំឱ្យការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមោឃៈ និង/ឬកំហុសអង្គហេតុដែលបានចោទប្រកាន់នោះ អាចធ្វើឱ្យមានភាពមិនយុត្តិធម៌ ដោយពុំបានធ្វើការពិនិត្យល្អិតល្អន់ក្នុងកម្រិតមួយដូចបានបញ្ជាក់នៅក្នុងសំណើសុំធ្វើការពិនិត្យឡើងវិញនោះ[12]

**កត់សម្គាល់ឃើញ**ថា ដោយហេតុថា ក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ពុំមានចែងអំពីការកែប្រែទម្រង់ការណ៍នៃបណ្តឹងសាទុក្ខបន្ទាប់ពីការដាក់សេចក្តីជូនដំណឹង ទើបពុំមានការហាមឃាត់ដាច់ខាតណាមួយលើការអនុវត្តន៍នេះឡើយ[13] ហើយអង្គជំនុំជម្រះតុលាការកំពូលពុំត្រូវបានរារាំងក្នុងការពិចារណាលើសំណើសុំការអនុញ្ញាតកែតម្រូវកំហុសលើខ្លឹមសារ និងក្នុងកាលៈទេសៈសមស្រប អាចប្រើប្រាស់យុត្តាធិការរបស់ខ្លួនក្នុងការរារាំងភាពមិនយុត្តិធម៌ដែលជាសក្តានុពល

**កត់សម្គាល់ផងដែរ**ថា អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចរបស់ខ្លួន ដោយពុំបានប៉ះពាល់ដល់សំណើនាពេលអនាគតដែលសុំបន្ថែមពេលវេលា ឬចំនួនទំព័រលើសារណាបណ្តឹងសាទុក្ខឡើយ

**ពិចារណាឃើញ**ថា ការមិនឯកភាពរបស់ ខៀវ សំផន ជាមួយសេចក្តីសម្រេចនោះ ពុំមែនជាការបង្ហាញនូវកំហុស ឬកាលៈទេសៈដែលអាចធ្វើយុត្តិកម្មឱ្យមានការពិចារណាឡើងវិញបានដើម្បីគេចវេះភាពមិនយុត្តិធម៌នោះឡើយ

**យល់ឃើញ**ថា សំណើសុំឱ្យពិចារណារឡើងវិញនេះ ពុំមានមូលដ្ឋានគាំទ្រ។

---

[11] វិធាន ១០៦(១), (៤) ដល់ (៥) និង ១០៧ នៃវិធានផ្ទៃក្នុង។

[12] *សូមមើល*សំណើសុំពិនិត្យឡើងវិញ កថាខណ្ឌ ១២។

[13] *ប្រៀបធៀប*សំណើសុំពិនិត្យឡើងវិញ កថាខណ្ឌ ៨ និង ១២។ សំណើសុំទីមួយ កថាខណ្ឌ ៧ ដល់ ១០។

**អាស្រ័យហេតុនេះ**

**បដិសេធសំណើនេះចោល។**

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៩

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**